**ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៨៧**

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

***

**តែងតាំង**

**លោក សុះ ភ៊ី**

**ជា**

**ខ្មកញ្ញា**

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៨ អនក្រ.បក

### ស្តីពីការបន្ថែមប្រាក់បៀវត្ស ជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម

★★★

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូលនិងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- យោងការសំរេចរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី០២ ខែមេសា ឆ្នាំ ១៩៩៩

**សំរេច**

**មាត្រា ១ .**_ ត្រូវបានអនុញ្ញាតអោយបន្ថែមប្រាក់បៀវត្ស ចំនួន ៣០ ភាគរយ លើបៀវត្សសុទ្ធសាធ ជូនមន្ត្រីរាជការស៊ីវិល យោធា នគរបាលជាតិ និវត្តជន និង មន្ត្រីបាត់បង់សមត្ថភាពពលកម្ម ។

**មាត្រា ២ .**_ ប្រាក់បៀវត្សដែលបន្ថែម ៣០ ភាគរយនេះ ត្រូវចាប់អនុវត្ត ពីខែ ឧសភា ឆ្នាំ ១៩៩៩ តទៅ ។

**មាត្រា ៣ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានជំរាបជូន**

សម្តេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ២៩ អនក្រ.បក

## ស្តីពីការកំណត់សមត្ថកិច្ចរបស់ខេត្ត ក្រុង

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា